

# សូមជួបជាមួយ អេតា

## មកពីអាមេរិក សាម័រ

*ជួបកុមារថ្នាក់អង្គការបឋមសិក្សាកំពុងជួយអ្នកដទៃ ដូចព្រះគ្រីស្ទបានធ្វើ ។*



### អ្វីៗអំពី អេតា



អាយុ ៖ ៩ ឆ្នាំ

ភាសា ៖
អង់គ្លេស និង កំពុងរៀនភាសាសាម័រ



មកពី ៖
អាមេរិក សាម័រ

គោលដៅ និងក្ដីសុបិន ៖
១). ចេញបេសកកម្ម ។
២) រៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ។
៣) រៀនចប់មហាវិទ្យាល័យ ។
៤) គ្រប់គ្រងហាងនំម៉ាក់របស់នាង ។



គ្រួសារ ៖
ម៉ាក់ ប៉ា បងប្អូនប្រុសពីរនាក់ និងបងស្រីម្នាក់



## ដៃជំនួយរបស់ អេតា

ម៉ាក់របស់ អេតា មានហាងនំមួយនៅលើកោះរបស់ពួកគេ ។ អេតា និងបងស្រីនាង តាឡាអ៊ី ចូលចិត្តចែកគេឯងញ៉ាំ ។ ជាមួយនឹងគ្រូបង្រៀន និងថ្នាក់ដឹកនាំរបស់ពួកគេ ព្រមទាំងជាមួយមនុស្សដែលក្រីក្រផងដែរ ។ ពេលខ្លះពួកគេជិះឡានជាមួយនឹងម៉ាក់ពួកគេ ហើយជូននំឃុកឃី និងនំផ្សេងទៀតទៅមនុស្សដែលពួកគេជួបតាមផ្លូវ ។ វាធ្វើឲ្យមនុស្សទាំងនោះរីករាយហើយវាធ្វើឲ្យ អេតា និងតាឡាអ៊ី រីករាយនឹងចែករំលែក ។ ពួកគេមានអំណរមកពីការចែករំលែក អាហារ និង នំមកពីហាងនំច្រើនជាងការញ៉ាំនំចំណីដោយខ្លួនឯង ! ពួកគេទាំងពីរនាក់កំពុងរៀនដុតនំ ដែលជាគោលដៅមួយសម្រាប់កម្មវិធីគោលដៅកុមារ និងយុវវ័យរបស់ពួកគេនៅឆ្នាំនេះ ដូច្នេះពួកគេមាននំចំណីចែករំលែកជានិច្ច ។

អេតា ថ្លែងថា « ខ្ញុំចូលចិត្តចែករំលែកជាមួយនឹងមនុស្សដទៃដោយសារវាធ្វើឲ្យពួកគេរីករាយ ហើយវាធ្វើឲ្យខ្ញុំរីករាយ ។ ខ្ញុំដឹងថា វាគឺជាអ្វីដែលព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យយើងធ្វើ » ។●



អេតា ( ខាងស្ដាំ ) កំពុងដុតនំជាមួយនឹងបងស្រីនាង តាឡាអ៊ី ។

អេតា ធ្វើតាមព្រះយេស៊ូវដោយការចែករំលែកជាមួយនឹងអ្នកស្សដទៃ ។ សូមបើកទំព័រដើម្បីអានរឿងមួយអំពីរបៀបដែលព្រះយេស៊ូវបានជួយអ្នកដទៃ ។

### ចំណង់ចំណូលចិត្ត របស់ អេតា



ទីកន្លែង ៖
អាងហែលទឹកតូចនៅលើកោះរបស់នាងជាកន្លែងដែលនាងចូលចិត្តទៅហែលទឹក



ពណ៌ ៖
ពណ៌ស្វាយ





ចម្រៀងកុមារ ៖
« យើងនិយាយដោយស្នេហ៍ » ( *សៀវភៅចម្រៀងកុមារ* ទំព័រ ១០២-១០៣ ) ។

ដំណើររឿងអំពីព្រះយេស៊ូវ ៖
នៅពេលទ្រង់មានព្រះជន្មរស់ឡើងវិញ



អាហារ ៖
អាហារបំពង



មុខវិជ្ជានៅសាលា ៖
គណិតវិទ្យា

« សូមយើងដាក់សេចក្ដីជំនឿរបស់យើងលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទទៅជាសកម្មភាពផង ! »

ប្រធាន រ័សុល អិម ណិលសុន « Opening the Heavens for Help » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ២០២០ ទំព័រ ៧៣ ។